**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Sep-2016, 15:03
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ(កោសលុប)**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង:

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើអនុលោមតាម ៨៧(៤) និងសំណើអនុលោមតាមវិធាន ៩៣ របស់ នួន ជា ពាក់ព័ន្ធនឹងអ្នកជំនាញដែលមានរហស្សនាម 2-TCE-82 (NAKAGAWA KASUMI)**

---

**<u>ដាក់ដោយ៖</u>**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ
Victor KOPPE
លីវ សុវណ្ណា
Doreen CHEN
ព្រុំ ផល្លា
Xiaoyang NIE
Marina HAKKOU
Léa KULINOWSKI
ឌី សុជាតា

**<u>ចម្លងជូន៖</u>**

**សហមេធាវីរបស់ ខៀវ សំផន៖**

គង់ សំអុន
Anta GUISSÉ

**សហព្រះរាជអាជ្ញា៖**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ
Marie GUIRAUD

## I. សេចក្តីផ្តើម

1. នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យភាគីដាក់សារណានានាអនុលោមតាមវិធាន ៨៧(៤) ទាក់ទិននឹងអ្នកជំនាញដែលមានរហស្សនាម 2-TCE-82 (NAKAGAWA Kasumi) ត្រឹមថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦[1]។ នៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានតែងតាំង 2-TCE-82 (NAKAGAWA Kasumi) ឱ្យមកផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញស្តីអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ("DK")[2]។

2. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សហមេធាវីការពារក្តីលោក នួន ជា ("មេធាវីការពារក្តី") សូមដាក់សំណើនេះ ("សំណើ") សុំឱ្យទទួលយកឯកសារចំនួន ២ ដែលពាក់ព័ន្ធនឹងអ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) ដែលនឹងមកផ្តល់សក្ខីកម្មនាពេលខាងមុខធ្វើជាភស្តុតាង។

3. លើសពីនេះទៀត អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង មេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ទៅអ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) ឱ្យផ្តល់កំណត់ហេតុនៃបទសម្ភាសន៍ដែលលោកស្រី និងនិស្សិតរបស់លោកស្រីបានរៀបចំ ដើម្បីរៀបរៀងការសិក្សារបស់លោកស្រីដែលមានចំណងជើងថា "អំពើហិង្សាលើយេនឌ័រក្នុងរបបខ្មែរក្រហម៖ រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីសម័យកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ១៩៧៥-១៩៧៩)" (ឯកសារ E3/2959) ព្រមទាំងកំណត់ហេតុនៃបទសម្ភាសន៍នានា នៅក្នុងបរិបទនៃការរៀបរៀងរបាយការណ៍របស់អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ដែលមានចំណងជើងថា "ខ្ញុំចង់និយាយប្រាប់អ្នក - រឿងរ៉ាវស្តីពីការរំលោភលើផ្លូវភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ១៩៧៥-១៩៧៩)" ដែលលោកស្រីបានចូលរួមចំណែក (ឯកសារ E3/3416) ដល់ភាគីនានា។

## II. ច្បាប់ជាធរមាន

---

[1] អ៊ីមែលពីមន្ត្រីច្បាប់នៃអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនភាគី "ការត្រៀមរៀបចំសម្រាប់ស្តាប់សក្ខីកម្មអ្នកជំនាញ 2-TCE-81 និង 2-TCE-82" ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៦។

[2] ឯកសារ **E431** "សេចក្តីសម្រេចស្តីពីការតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-82" ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦។

## ក. វិធាន ៨៧(៤)

4. រាល់ភ័ស្តុតាងទាំងអស់អាចទទួលយកបានដរាបណាពុំមានបទប្បញ្ញត្តិណាមួយនៅក្នុងវិធានផ្ទៃក្នុងចែងផ្ទុយពីនេះ[3]។ អង្គជំនុំជម្រះអាចច្រានចោលសំណើសុំភ័ស្តុតាងបាន ក្នុងករណីអង្គជំនុំជម្រះយល់ឃើញថាមិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ មិនសមស្របសម្រាប់ការបញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភ័ស្តុតាងច្បាប់មិនអនុញ្ញាត ឬប្រសិនបើភ័ស្តុតាងនោះមានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬជាភ័ស្តុតាងគ្មានប្រយោជន៍[4]។ ដើម្បីបំពេញលក្ខខណ្ឌនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ភ័ស្តុតាងដែលបានស្នើឡើងនោះគ្រាន់តែចាំបាច់ត្រូវមានភាពពាក់ព័ន្ធ និងអាចទុកចិត្តបានជាបឋម តែប៉ុណ្ណោះ[5]។ អនុលោមតាមវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង ភាគីអាចស្នើសុំអង្គជំនុំជម្រះឱ្យ "ទទួលយកភ័ស្តុតាងថ្មីដែលអង្គជំនុំជម្រះយល់ឃើញថាអាចជួយដល់ការបញ្ជាក់ការពិត" ទោះក្នុងដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធីក៏ដោយ ដរាបណាបានគោរពតាមលក្ខខណ្ឌទូទៅនៅក្នុងវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង[6]។ ទោះបីជាវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងចែងថា ភ័ស្តុតាងដែលបានស្នើសុំត្រូវជាភ័ស្តុតាងដែលពុំអាចរកបាននៅមុនពេលចាប់ផ្តើមការជំនុំជម្រះក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានបកស្រាយវិធាននេះថា ភ័ស្តុតាង ដែលរាប់បញ្ចូលទាំងភ័ស្តុតាងដែលអាចរកបាននៅមុនពេលចាប់ផ្តើមការជំនុំជម្រះ ក៏ប៉ុន្តែពុំអាចរកឃើញនៅមុននោះ ទោះបីជាបានខិតខំប្រឹងប្រែងយ៉ាង

---

[3] វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។

[4] វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

[5] ឯកសារ **E289/2** "សេចក្តីសម្រេចលើសំណើដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលសុំដាក់ភ័ស្តុតាងថ្មីនៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ E289) និងចម្លើយតបរបស់ ខៀវ សំផន (ឯកសារ E389/1)" ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ២៦ ("សេចក្តីសម្រេចអនុលោមតាមវិធាន ៨៧(៤)")។

[6] នៅពេលការជំនុំជម្រះលើសំណុំរឿង ០០២/០២ ដំណើរការបានមួយឆ្នាំ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ភាគីត្រូវដាក់សំណើសុំអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងស្នើសុំឯកសារដែលនៅក្នុងសំណុំរឿងប៉ុន្តែពុំត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសារដែលបានទទួលយកដោយអង្គជំនុំជម្រះសាលាដំបូងបើទោះជាឯកសារទាំងនោះត្រូវបានដាក់បង្ហាញដោយការិយាល័យសហព្រះរាជអាជ្ញានាពេលក្រោយមកបន្ទាប់ពីការដាក់ឯកសារនាពេលដំបូងក៏ដោយ សូមមើល ប្រតិចារឹកសវនាការ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ (សេចក្តីសម្រេចផ្ទាល់មាត់) ទំព័រ ២៤ បន្ទាត់ ១១-១៣ (ភាសាអង់គ្លេស)។

យកចិត្តទុកដាក់យ៉ាងណាក៏ដោយ អាចទទួលយកបាន[7]។

5. នៅក្នុងស្ថានភាពជាក់ស្តែងភ័ស្តុតាងដែល "លើកឡើងដោយមិនតឹងរ៉ឹង" បំពេញលក្ខខណ្ឌនេះអាចទទួលយកបានគឺ: នៅពេលដែលភស្តុតាងមានភាពពាក់ព័ន្ធយ៉ាងខ្លាំងទៅឯកសារដែលមានស្រាប់នៅចំពោះមុខអង្គជំនុំជម្រះនិងនៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យមានប្រភពដើម្បីវាយតម្លៃ និងនៅពេលដែលភស្តុតាងដែលស្នើគឺជាភ័ស្តុតាងដោះបន្ទុក និងតម្រូវឲ្យមានការវាយតម្លៃដើម្បីកុំឲ្យប៉ះពាល់ដល់យុត្តិធម៌ ឬក៏នៅពេលដែលភាគីផ្សេងទៀតមិនបានជំទាស់ទៅនឹងភស្តុតាងនេះ[8]។

## ខ. វិធាន ៩៣

6. វិធាន ៩៣ នៃវិធានផ្ទៃក្នុងអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យមានកិច្ចស៊ើបសួរបន្ថែមគ្រប់ពេលនៃដំណើរការកិច្ចនីតិវិធី ក្នុងករណីអង្គជំនុំជម្រះយល់ឃើញថាចាំបាច់[9]។ ការស៊ើបអង្កេតអាចរួមមាន *ក្នុងចំណោមនោះ* ការស្តាប់ចម្លើយសាក្សី ធ្វើការឆែកឆេរ ឬ ចាប់យកភ័ស្តុតាង ឬបង្គាប់ឲ្យធ្វើកោលសលវិច័យ។ ការស៊ើបអង្កេតបន្ថែមបែបនេះត្រូវធ្វើឡើងក្រោមលក្ខខណ្ឌដូចគ្នានឹងលក្ខខណ្ឌអនុវត្តរបស់សហចៅក្រមស៊ើបអង្កេត[10]។ លក្ខណវិនិច្ឆ័យស្តីពីភាពចាំបាច់នៅក្នុងវិធាន ៩៣ មានន័យថា ការស៊ើបអង្កេតត្រូវតែធ្វើឡើងដើម្បីជាប្រយោជន៍នៃយុត្តិធម៌[11]។ ម្យ៉ាងវិញទៀត ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវតែពិនិត្យក្នុងបរិបទនៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក រួមទាំងសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងឆាប់រហ័ស[12]។

## គ. អ្នកជំនាញ

[7] ឯកសារ **E313** "សាលក្រមលើសំណុំរឿង ០០២/០១" ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ២៥។ ឯកសារ **E289/2** សេចក្តីសម្រេចលើសំណើសុំអនុលោមតាមវិធាន ៨៧(៤) កថាខណ្ឌ ៣។

[8] ឯកសារ **E289/2** សេចក្តីសម្រេចលើសំណើសុំអនុលោមតាមវិធាន ៨៧(៤) កថាខណ្ឌ ៣។

[9] វិធាន ៩៣(១) នៃវិធានផ្ទៃក្នុង។

[10] វិធាន ៩៣(២) នៃវិធានផ្ទៃក្នុង។

[11] ឯកសារ **E294/1** "សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឲ្យទទួលយកភ័ស្តុតាងថ្មី ឲ្យចាប់ផ្តើមការស៊ើបអង្កេត និងឲ្យកោះហៅលោក ROB LEMKIN" ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ១១។

[12] *ដូចយោងខាងលើ*។

7. នៅគ្រប់ពេលវេលាទាំងអស់ អង្គជំនុំជម្រះសាលាដំបូងត្រូវធានាថា ការជំនុំជម្រះត្រូវមានភាពយុត្តិធម៌ និងឆាប់រហ័ស ហើយត្រូវធ្វើឡើងដោយគោរពសិទ្ធិជនជាប់ចោទឱ្យបានពេញលេញ និងការពារជនរងគ្រោះ និងសាក្សី[13]។ ជាពិសេស ប្រធានអង្គជំនុំជម្រះត្រូវធានានូវការអនុវត្តសិទ្ធិការពារក្តីដោយសេរី អនុលោមតាមវិធាន ៨៥(១) នៃវិធានផ្ទៃក្នុង។

8. គ្រប់ជនជាប់ចោទនៅចំពោះមុខតុលាការនេះមានសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន[14] ពិនិត្យភ័ស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួម និងការពិនិត្យភ័ស្តុតាងដោះបន្ទុក ក្នុងលក្ខខណ្ឌដូចគ្នានឹងភ័ស្តុតាងដាក់បន្ទុក[15]។ អង្គជំនុំជម្រះសាលាដំបូងមានភារកិច្ចការពារសិទ្ធិទាំងនេះ និងធ្វើយ៉ាងណាឱ្យការជំនុំជម្រះដំណើរការទៅដោយយុត្តិធម៌ និងឆាប់រហ័ស ដោយត្រូវគោរពពេញលេញលើសិទ្ធិរបស់ជនជាប់ចោទ និងការពារដល់ជនរងគ្រោះ និងសាក្សីផងដែរ[16]។ ជាពិសេសប្រធានអង្គជំនុំជម្រះត្រូវ ធានាដល់ការអនុវត្តសិទ្ធិការពារខ្លួនឱ្យប្រព្រឹត្តដោយសេរី[17]។

9. វិធាន ៣១ នៃវិធានផ្ទៃក្នុង បញ្ញត្តិអំពីការតែងតាំងអ្នកជំនាញដោយ អ.វ.ត.ក។ វិធាននេះពុំមានបទប្បញ្ញត្តិចែងទាក់ទងនឹងប្រភពដែលអ្នកជំនាញសំអាងនៅក្នុងរបាយការណ៍/ភ័ស្តុតាងរបស់គេនោះទេ។

10. មាត្រា ៣៣ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ចែងថា ប្រសិនបើនីតិវិធី អ.វ.ត.ក ជាធរមានមិនមានចែងអំពីបញ្ហាជាក់លាក់ណាមួយ ឬប្រសិនបើមានភាពពុំច្បាស់លាស់ទាក់ទងនឹងការបកស្រាយ ឬការអនុវត្ត ឬ ប្រសិនបើមានបញ្ហាចោទ ទាក់ទិននឹងភាពស៊ីសង្វាក់គ្នាជាមួយនឹងបទដ្ឋានអន្តរជាតិ តុលាការអាចមើលការណែនាំនៅក្នុង វិធាននីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិបាន។ ដូច្នេះ ការអនុវត្ត និងយុត្តិសាស្ត្រនៃសាលាក្តី

---

[13] មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[14] មាត្រា ៣៥(ខ) ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (“ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក”)។

[15] មាត្រា ៣៥(ង) ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[16] មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[17] វិធាន ៨៥ នៃវិធានផ្ទៃក្នុង។

អន្តរជាតិផ្សេងទៀតផ្តល់ជាការណែនាំដ៏សំខាន់។

11. សាលាក្តី ICTY បានសម្រេចថា "តុលាការរំពឹងថា សាក្សីជំនាញនឹងផ្តល់យោបល់ជំនាញរបស់គាត់ដោយមានតម្លាភាពពេញលេញអំពីអង្គហេតុដែលបានរកឃើញ ឬត្រូវបានសន្មត ដែលអ្នកជំនាញបានសំអាង និងវិធីសាស្ត្រដែលបានប្រើនៅពេលប្រើប្រាស់ការយល់ដឹង បទពិសោធន៍ ឬជំនាញរបស់ខ្លួន ដើម្បីបង្កើតយោបល់ជំនាញរបស់គាត់"[18]។ ដូច្នេះ ត្រូវមានព័ត៌មានគ្រប់គ្រាន់អំពីប្រភពដែលបានប្រើប្រាស់ដើម្បីគាំទ្រការលើកឡើងរបស់អ្នកជំនាញ[19]។ ជាពិសេស ប្រភពដែលបានប្រើប្រាស់ដោយសាក្សីជំនាញត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ និងអាចពិនិត្យមើលបាន[20] ដើម្បី

[18] សាលាក្តី ICTY៖ ឯកសារ **E405.1.3** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Galić* សំណុំរឿងលេខ IT-98-29-T សេចក្តីសម្រេចទាក់ទងនឹងសាក្សីជំនាញ Ewa Tabeau និង Richard Philipps ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០២ ទំព័រ ២។ ឯកសារ **E405.1.4** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Galić* សំណុំរឿងលេខ IT-98-29-T សេចក្តីសម្រេចលើញត្តិរបស់អយ្យការសុំឱ្យពិចារណាឡើងវិញលើការទទួលយករបាយការណ៍កោសល្យវិច័យរបស់សាស្ត្រាចារ្យ Radinović ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ ៩។ ឯកសារ **E405.1.5** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Gotovina និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-06-90-T សេចក្តីសម្រេចលើការដាក់បង្ហាញសម្ភារៈរបស់អ្នកជំនាញ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ កថាខណ្ឌ ១០។

[19] សាលាក្តី ICTY៖ ឯកសារ **E405.1.6** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stanišić & Župljanin* សំអាងហេតុជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយក Hanson របស់ Dorothea ជាសាក្សីជំនាញ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ១០។ ឯកសារ **E405.1.7** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង D. Milošević* សំណុំរឿងលេខ IT-98-29/1-T សេចក្តីសម្រេចលើការទទួលយករបាយការណ៍កោសល្យវិច័យរបស់ Robert Donia ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៧ កថាខណ្ឌ ៨។ ឯកសារ **E405.1.8** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karadžić* សំណុំរឿងលេខ IT-95-5/18-T សេចក្តីសម្រេចលើញត្តិរបស់អយ្យការសុំដកចេញរបាយការណ៍កោសល្យវិច័យរបស់ Kosta Čavoški ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣ កថាខណ្ឌ ២២។

[20] សាលាក្តី ICTY៖ ឯកសារ **E405.1.6** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stanišić & Župljanin* សំអាងហេតុជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយក Hanson របស់ Dorothea ជាសាក្សីជំនាញ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ១០។ ឯកសារ **E405.1.7** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង D. Milošević* សំណុំរឿងលេខ IT-98-29/1-T សេចក្តីសម្រេចលើការទទួលយករបាយការណ៍កោសល្យវិច័យរបស់ Robert Donia ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៧ កថាខណ្ឌ ៨។ ឯកសារ **E405.1.8** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karadžić* សំណុំរឿងលេខ IT-95-5/18-T សេចក្តីសម្រេចលើញត្តិរបស់អយ្យការសុំដកចេញរបាយការណ៍កោសល្យវិច័យរបស់ Kosta Čavoški ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣ កថាខណ្ឌ ២២។ ឯកសារ **E405.1.4** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Galić* សំណុំរឿងលេខ IT-98-29-T សេចក្តីសម្រេចលើញត្តិរបស់អយ្យការសុំឱ្យពិចារណាឡើងវិញលើការទទួលយករបាយការណ៍កោសល្យវិច័យរបស់សាស្ត្រាចារ្យ Radinović ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ ៩។ ឯកសារ **E405.1.5** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Gotovina និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-06-90-T សេចក្តីសម្រេចលើការដាក់បង្ហាញសម្ភារៈរបស់អ្នកជំនាញ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ កថាខណ្ឌ ១០។

អនុញ្ញាតឱ្យភាគីម្ខាងទៀតជំទាស់មូលដ្ឋានដែលសាក្សីជំនាញបានទាញការសន្និដ្ឋាន ឬ វិធីសាស្ត្ររបស់សាក្សីអ្នកជំនាញ[21]។

12. ប្រសិនបើភាគី និងអង្គជំនុំជម្រះសាលាដំបូង មិនអាចវាយតម្លៃទៅលើតម្លៃជាភ័ស្តុតាងនៃរបាយការណ៍របស់អ្នកជំនាញដែលបានស្នើឡើង ដោយសារកង្វះតម្លាភាព របាយការណ៍នេះអាចថាមិនត្រូវទទួលយកមកធ្វើជាភ័ស្តុតាង ឬក៏ថា អង្គជំនុំជម្រះអាចផ្តល់ទម្ងន់តិចតួចប៉ុណ្ណោះលើរបាយការណ៍នោះ[22]។ ដោយសារមិនមានការយោងច្បាស់លាស់ ឬប្រភពដែលអាចពិនិត្យមើលបាន សាលាក្តី ICTY នឹងមិនចាត់ទុកការលើកឡើង ឬរបាយការណ៍នេះថាជាមតិយោបល់របស់*អ្នកជំនាញ* នោះទេ ប៉ុន្តែចាត់ទុកជាមតិយោបល់*ផ្ទាល់ខ្លួន*របស់សាក្សី ហើយផ្តល់ទម្ងន់ទៅតាមនោះ[23]។ អាចនិយាយម្យ៉ាងទៀតថា ផ្នែកនៃរបាយការណ៍ និង/ឬសក្ខីកម្មដែលមានប្រភពមិន

---

[21] សាលាក្តី ICTY៖ ឯកសារ **E405.1.6** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stanišić & Župljanin* សំអាងហេតុជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយក Hanson របស់ Dorothea ជាសាក្សីជំនាញ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ១០។ ឯកសារ **E405.1.7** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង D. Milošević* សំណុំរឿងលេខ IT-98-29/1-T សេចក្តីសម្រេចលើការទទួលយករបាយការណ៍កោសល្យវិច័យរបស់ Robert Donia ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៧ កថាខណ្ឌ ៨។ ឯកសារ **E405.1.8** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karadžić* សំណុំរឿងលេខ IT-95-5/18-T សេចក្តីសម្រេចលើញត្តិរបស់អយ្យការសុំដកចេញរបាយការណ៍កោសល្យវិច័យរបស់ Kosta Čavoški ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣ កថាខណ្ឌ ២២។ ឯកសារ **E405.1.4** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Galić* សំណុំរឿងលេខ IT-98-29-T សេចក្តីសម្រេចលើញត្តិរបស់អយ្យការសុំឱ្យពិចារណាឡើងវិញលើការទទួលយករបាយការណ៍កោសល្យវិច័យរបស់សាស្ត្រាចារ្យ Radinović ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ ៩។ ឯកសារ **E405.1.5** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Gotovina និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-06-90-T សេចក្តីសម្រេចលើការដាក់បង្ហាញសម្ភារៈរបស់អ្នកជំនាញ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ កថាខណ្ឌ ១០។

[22] សាលាក្តី ICTY៖ ឯកសារ **E405.1.5** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Gotovina និងអ្នកផ្សេងទៀត* IT-06-90-T សេចក្តីសម្រេចលើការដាក់បង្ហាញសម្ភារៈរបស់អ្នកជំនាញ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ កថាខណ្ឌ ១០។

[23] សាលាក្តី ICTY៖ ឯកសារ **E405.1.7** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង D. Milošević* សំណុំរឿងលេខ IT-98-29/1-T សេចក្តីសម្រេចលើការទទួលយករបាយការណ៍កោសល្យវិច័យរបស់ Robert Donia ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៧ កថាខណ្ឌ ៨។ ឯកសារ **E405.1.9** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Martić* សំណុំរឿងលេខ IT-95-11-T សេចក្តីសម្រេចលើសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីលើរបាយការណ៍កោសល្យវិច័យរបស់សាស្ត្រាចារ្យ អនុលោមតាមវិធាន ៩៤*ស្ទួន* ចុះថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ ៩។ ឯកសារ **E405.1.4** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Galić* សំណុំរឿងលេខ IT-98-29-T សេចក្តីសម្រេចលើញត្តិរបស់អយ្យការសុំឱ្យពិចារណាឡើងវិញលើការទទួលយករបាយការណ៍កោសល្យវិច័យរបស់សាស្ត្រាចារ្យ Radinović ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ ៩។ *សូមមើលផងដែរ* ឯកសារ **E405.1.8** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karadžić* សំណុំរឿងលេខ IT-95-5/18-T សេចក្តីសម្រេចលើញត្តិរបស់អយ្យការសុំដកចេញរបាយការណ៍កោសល្យវិច័យរបស់ Kosta Čavoški ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣ កថាខណ្ឌ ២២។

ច្បាស់លាស់ ឬក្នុងករណីដែលភាគីមិនមានឱកាសពិនិត្យ ឬតវ៉ាសាក្សីដែលបានផ្តល់ព័ត៌មាន នឹងត្រូវបានផ្តល់ទម្ងន់តិចតួចប៉ុណ្ណោះ ប្រសិនបើផ្តល់ឱ្យនោះ[24]។

13. ជាលទ្ធផល វាជាការអនុវត្តមួយច្បាស់លាស់នៅសាលាក្តី ICTY ដែលថា ភាគីដែលកោះហៅអ្នកជំនាញបង្ហាញរបាយការណ៍អ្នកជំនាញ រួមជាមួយនឹងប្រភពដែលបានប្រើប្រាស់សម្រាប់របាយការណ៍នោះ[25]។ តុលាការ ICC បានក៏បានអនុវត្តតាមការអនុវត្តនេះដែរ[26]។

14. លើសពីនេះទៀត តុលាការ ICC បានសម្រេចថា បញ្ហាទាំងឡាយជុំវិញប្រភពដែលបានប្រើប្រាស់ ឬ ការលើកយោង វចនាសម្ព័ន្ធ ឬវិធីសាស្ត្រនៃរបាយការណ៍ គឺជាបញ្ហាដែលអាចលើកឡើងនៅក្នុងអំឡុងពេលសួរដេញដោល និងត្រូវយកមកពិចារណានៅពេលវាយតម្លៃលើទម្ងន់នៃរបាយការណ៍នេះ ប្រសិនបើត្រូវទទួលយកនោះ[27]។

---

[24] សាលាក្តី ICTY៖ ឯកសារ **E405.1.4** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Galić* សំណុំរឿងលេខ IT-98-29-T សេចក្តីសម្រេចលើញត្តិរបស់អយ្យការសុំឱ្យពិចារណាឡើងវិញលើការទទួលយករបាយការណ៍កោសល្យវិច័យរបស់សាស្ត្រាចារ្យ Radinović ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ ៩។

[25] *សូមមើល ខ.* សាលាក្តី ICTY៖ ឯកសារ **E405.1.10** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stanišić និង Simatović* សំណុំរឿងលេខ IT-03-69-PT សេចក្តីសន្និដ្ឋានរបស់អយ្យការលើរបាយការណ៍កោសល្យវិច័យរបស់ Christian Nielsen អនុលោមតាមវិធាន ៩៤*ស្ទួន* ជាមួយនឹងឧបសម្ព័ន្ធ ក និង ខ ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៧ កថាខណ្ឌ ១។ ឯកសារ **E405.1.3** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karadžić* សំណុំរឿងលេខ IT-95-5/18-T ញត្តិរបស់អយ្យការសុំទទួលយកភស្តុតាងរបស់អ្នកជំនាញចំនួន ៨ នាក់ អនុលោមតាមវិធាន ៩៤*ស្ទួន* និងវិធាន ៩២*ស្ទួន* ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ២០០៩ កថាខណ្ឌ ១៧។ ឯកសារ **E405.1.9** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Mladić* សំណុំរឿងលេខ IT-09-92-T សេចក្តីជូនដំណឹងរបស់អយ្យការលើការដាក់បង្ហាញរបាយការណ៍កោសល្យវិច័យរបស់ Andras Riedlmayer (RM 618) អនុលោមតាមវិធាន ៩៤*ស្ទួន* និងញត្តិសុំកែប្រែបញ្ជីវត្ថុតាងយោងតាមវិធាន ៦៥*ស្ទួនពីរ* ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០១៣ កថាខណ្ឌ ៧។

[26] តុលាការ ICC៖ ឯកសារ **E405.1.13** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Bemba និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ICC-01/05-01/13 ចម្លើយតបរបស់អយ្យការទៅនឹងសំណើរួមរបស់មេធាវីការពារក្តីអនុលោតាមបទប្បញ្ញត្តិ ៣៥ នៃបទប្បញ្ញត្តិរបស់តុលាការក្នុងការព្យួរសេចក្តីជូនដំណឹងទាក់ទងនឹងសាក្សីជំនាញ (លេខ ICC-01/05-01/13-1242) ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ កថាខណ្ឌ ៥។ ឯកសារ **E405.1.14** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Bemba និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ICC-01/05-01/13 សេចក្តីសម្រេចលើសំណើរួមរបស់មេធាវីការពារក្តីអនុលោតាមបទប្បញ្ញត្តិ ៣៥ នៃបទប្បញ្ញត្តិរបស់តុលាការក្នុងការព្យួរសេចក្តីជូនដំណឹងទាក់ទងនឹងសាក្សីជំនាញ (លេខ ICC-01/05-01/13-1280) ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ កថាខណ្ឌ ១១។

[27] តុលាការ ICC៖ ឯកសារ **E405.1.15** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ntaganda* សំណុំរឿងលេខ ICC-01/04-02/06 សេចក្តីសម្រេចលើចម្លើយតបរបស់អយ្យការទៅនឹងការជំទាស់បឋមលើសាក្សីជំនាញរបស់អយ្យការ (លេខ ICC-01/04-

## III. ឧទ្ទិករណ៍

## ក. សំណើអនុលោមតាមវិធាន ៨៧(៤)

### *(i) ចិរភាពទូទៅនៃឯកសារ*

15. ឯកសារទីមួយដែលមេធាវីការពារក្តីមានបំណងចង់ឱ្យទទួលយកធ្វើជាភ័ស្តុតាងគឺប្រវត្តិរូបការងាររបស់អ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) ដែលបានទទួលពីអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦[28]។ ឯកសារនេះពាក់ព័ន្ធនឹងប្រវត្តិ និងជំនាញរបស់អ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) ដែលពាក់ព័ន្ធនឹងការចាត់តាំងលោកស្រីជាសាក្សីជំនាញនៅក្នុងសំណុំរឿងនេះ និងទម្ងន់ដែលត្រូវផ្តល់ទៅភ័ស្តុតាងរបស់លោកស្រី។

16. ឯកសារទីពីរ គឺជារបាយការណ៍របស់អ្នកជំនាញស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងអំឡុងមានជម្លោះនៅប្រទេសសៀរ៉ាឡេអូន ដែលបានរៀបរៀងដោយ Zainab H. Bangura និង Christiana T. Solomon នៅខែ ឧសភា ឆ្នាំ ២០០៥ សម្រាប់រដ្ឋអាជ្ញានៅតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ("SCSL")[29]។ ឯកសារនេះមាននៅក្នុង**ឯកសារបន្ថែមសាធារណៈ ១**។ របាយការណ៍នេះពិភាក្សាអំពីបរិបទ អត្ថន័យ និងផលវិបាកនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងជាពិសេស បាតុភូតនៃ "bush wives" ("ស្ត្រីដែលត្រូវបានគេចាប់បង្ខំទៅធ្វើជាប្រពន្ធទាហាន") ក្នុងអំឡុងពេលមានសង្គ្រាមស៊ីវិលនៅប្រទេសសៀរ៉ាឡេអូន។ ដោយសារតុលាការនេះ

---

02/06-1159) ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៦ កថាខណ្ឌ ១៦។ ឯកសារ **E405.1.16** រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ruto & Sang*, សំណុំរឿងលេខ ICC-01/09-01/11 សេចក្តីសម្រេចលើពាក្យសុំរបស់មេធាវីការពារក្តី Sang សុំដកចេញរបាយការណ៍ជំនាញរបស់លោក Hervé Maupeu (លេខ ICC-01/09-01/11-844) ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ២០១៣ កថាខណ្ឌ ២៧។

[28] ឯកសារ **E431.1** ភ្ជាប់ទៅនឹងឯកសារ **E431** "សេចក្តីសម្រេចស្តីពីការតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-82" ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦។ ឯកសារនេះត្រូវបានដាក់ស្នើសុំឱ្យបកប្រែជាភាសាបារាំង និង ភាសាខ្មែរនៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦។

[29] របាយការណ៍របស់អ្នកជំនាញស្តីពីបាតុភូតនៃ "ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ" នៅក្នុងបរិបទនៃជម្លោះនៅប្រទេសសៀរ៉ាឡេអូន និង ពិសេសជាងនេះទៀត នៅក្នុងបរិបទនៃការជំនុំជម្រះប្រឆាំងនឹងជនជាប់ចោទដែលជាសមាជិក RUF និង AFRC របស់ Zainab H. Bangura និង Christiana T. Solomon ខែ ឧសភា ឆ្នាំ ២០០៥ មាននៅក្នុងឧបសម្ព័ន្ធមួយភ្ជាប់នឹងតុលាការ SCSL សំណុំរឿងលេខ SCSL-2004-16-T ការដាក់របាយការណ៍របស់អ្នកជំនាញពីអយ្យការ អនុលោមតាមវិធាន ៩៤(*ស្ទួន*) និងសេចក្តីទៅលើសំណើរបស់អយ្យការដែលសុំការអនុញ្ញាតការកោះហៅសាក្សីជំនាញបន្ថែម ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០០៥។ ឯកសារនេះត្រូវបានដាក់ស្នើសុំឱ្យបកប្រែជាភាសាបារាំង និង ភាសាខ្មែរនៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦។

ជាតុលាការមុនគេ និងជាតុលាការតែមួយគត់ដែលមានយុត្តាធិការលើបទឧក្រិដ្ឋកម្មអន្តរជាតិ ដែលសម្រេចទៅលើបញ្ហាស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងដោយសាររបាយការណ៍របស់អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាស្តីពីអំពើហិង្សាផ្លូវភេទ ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ (ឯកសារ E3/3416) ដែលអ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) ជាជំនួយការស្រាវជ្រាវ និង ជាមន្ត្រីគ្រប់គ្រងគម្រោង មានការយោង និងការប្រៀបធៀបជាមួយនឹងស្ថានភាពរបស់ស្ត្រីនៅក្នុងពេលមានជម្លោះនៅប្រទេសសៀរ៉ាឡេអូន[30] នោះ មេធាវីការពារក្តីចង់ពិភាក្សាស្ថានភាពនៅប្រទេសសៀរ៉ាឡេអូនជាមួយអ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) ដោយយោងទៅរបាយការណ៍របស់អ្នកជំនាញ។

### (ii) *ឯកសារមានភាពពាក់ព័ន្ធ ភាពជឿជាក់បាន និង យថាភាព*

17. ឯកសារចំនួន ២ ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការសិក្សាដែលអ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) បានរៀបរៀង គឺ ឯកសារ E3/2959[31] និង របាយការណ៍របស់អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាស្តីពីអំពើហិង្សាផ្លូវភេទក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យដែលលោកស្រីបានចូលរួមចំណែក[32]។ ក្រៅពីនេះ ឯកសារទាំងនេះមានទំនាក់ទំនងទៅនឹងបទចោទស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលមាននៅ *ក្នុងចំណោមនោះ* កថាខណ្ឌ ៣០៦-៣២៤, ១៤៣០-១៤៣៣, ១៤៤២-១៤៤៧ នៃដីកាដំណោះស្រាយ[33]។ ឯកសារទាំងពីរនេះអាចជឿជាក់បាន និងមានយថាភាព ដោយសារអ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) ជាអ្នករៀបរៀងឯកសារមួយដោយលោកស្រីផ្ទាល់។ ឯកសារមួយទៀតត្រូវបានរៀបរៀងដោយបុគ្គលដែលតុលាការពិសេសប្រទេសសៀរ៉ាឡេអូនបានទទួលស្គាល់ថាជាអ្នកជំនាញ ហើយត្រូវបានទទួលយកធ្វើជាភស្តុតាង។

### (iii) *ត្រូវតែទទួលយកឯកសារជាភស្តុតាងដើម្បីជាប្រយោជន៍យុត្តិធម៌*

---

[30] ឯកសារ **E3/3416** “ខ្ញុំចង់និយាយប្រាប់អ្នក - រឿងរ៉ាវស្តីពីការរំលោភលើផ្លូវភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ១៩៧៥-១៩៧៩)” អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា លេខ ERN ភាសាអង់គ្លេស 00449473, 00449498, 00449504។

[31] ឯកសារ **E3/2959** “រឿងរ៉ាវរបស់អ្នកនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ១៩៧៥-១៩៧៩)” NAKAGAWA Kasumi ខែ ធ្នូ ឆ្នាំ ២០០៨។

[32] ឯកសារ **E3/3416** “ខ្ញុំចង់និយាយប្រាប់អ្នក - រឿងរ៉ាវស្តីពីការរំលោភលើផ្លូវភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ១៩៧៥-១៩៧៩)” អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា។

[33] ឯកសារ **D427** “ដីកាដំណោះស្រាយ” ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០។

18. ការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ បានចាប់ផ្តើមនៅខែ មិថុនា ឆ្នាំ ២០១១[34]។ ភាគីអាចរកប្រវត្តិរូបការងាររបស់អ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) បាន នៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦[35]។ ទោះបីជារបាយការណ៍អ្នកជំនាញស្តីពីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅប្រទេសសៀវ៉ាឡេអូន អាចរកបានមុនពេលចាប់ផ្តើមការជំនុំជម្រះក៏ដោយ តែភាគីទើបតែបានទទួលព័ត៌មានអំពីសក្ខីកម្មដែលអ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) នឹងមកផ្តល់នាពេលខាងមុខ នៅថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១៦ ប៉ុណ្ណោះ។ យ៉ាងណាក៏ដោយ របាយការណ៍នេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសម្ភារៈដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ រួមទាំងឯកសារ E3/3416 និងឯកសារ E3/2959[36]។ មេធាវីការពារក្តីលើកឡើងថា ប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងយកឯកសារមកវាយតម្លៃរួមគ្នា។ ចុងក្រោយ ការទទួលយកឯកសារដែលបានស្នើសុំចំនួន ២ ធ្វើជាភ័ស្តុតាង នឹងជួយអង្គជំនុំជម្រះសាលាដំបូងក្នុងការបំភ្លឺអំពីជំនាញរបស់អ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) និងអំពីភ័ស្តុតាងរបស់លោកស្រីទាក់ទិននឹងការចេញបទបញ្ជាអំពីការរៀបអាពាហ៍ពិពាហ៍ ដែលជាប្រយោជន៍ក្នុងការស្វែងរកការពិតជាទូទៅ។

## ខ. សំណើអនុលោមតាមវិធាន ៨៣

19. អង្គជំនុំជម្រះសាលាដំបូងបានយោងទៅឯកសារ E3/2959 និងឯកសារ E3/3416 ដើម្បីគាំទ្រដល់សេចក្តីសម្រេចក្នុងការតែងតាំង 2-TCE-82 (NAKAGAWA Kasumi) ជាអ្នកជំនាញ[37] ហើយសន្មតថា ឯកសារទាំងនេះនឹងបង្កើតជាមូលដ្ឋានសម្រាប់ភាគីក្នុងការតាំងសំណួរដល់លោកស្រី។

---

[34] ឯកសារ **E307/1** "សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧(៤) (ឯកសារ E307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភ័ស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/3)" ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ ២; ឯកសារ **E307/1/2** "សេចក្តីសម្រេចលើសំណើរួមសុំឱ្យសម្រេច *សាជាថ្មីឡើងវិញ*លើការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង" ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ៦។

[35] ឯកសារ **E431** "សេចក្តីសម្រេចស្តីពីការតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-82" ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦។

[36] ឯកសារ **E3/2959** "រឿងរ៉ាវរបស់អ្នកនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ១៩៧៥-១៩៧៩)" NAKAGAWA Kasumi ខែ ធ្នូ ឆ្នាំ ២០០៨; ឯកសារ **E3/3416** "ខ្ញុំចង់និយាយប្រាប់អ្នក - រឿងរ៉ាវស្តីពីការរំលោភលើផ្លូវភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ១៩៧៥-១៩៧៩)" អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា។

[37] ឯកសារ **E431** "សេចក្តីសម្រេចស្តីពីការតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-82" ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ កថាខណ្ឌ ១៣។

ដើម្បីវាយតម្លៃ និងជំទាស់ទៅនឹងភស្តុតាងរបស់អ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) ឱ្យបានត្រឹមត្រូវ មេធាវីការពារក្តីចាំបាច់ត្រូវទទួលការអនុញ្ញាតឱ្យពិនិត្យមើលបទសម្ភាសន៍ជាក់ស្តែងដែលបង្កើតជាមូលដ្ឋានសម្រាប់ស្នាដៃបោះពុម្ពផ្សាយទាំងពីរនេះ។

*(i)* ***ឯកសារដែលបានស្នើសុំ***

20. នៅក្នុងឯកសារ E3/2959 អ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) ចង្អុលបង្ហាញថា ការសិក្សាផ្អែកលើប្រភពចំនួន ២ ប្រភេទ៖

(i) បទសម្ភាសន៍ជាមួយមនុស្សប្រហែល ១០០ នាក់ ក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ចំនួន ១៥០០ នាក់ ដែលត្រូវបានជ្រើសរើស "ក្នុងគោលបំណងកត់ត្រាអំពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់ពួកគេអំពីឧក្រិដ្ឋកម្មផ្អែកយេនឌ័រនៅសម័យ" កម្ពុជាប្រជាធិបតេយ្យ។ បទសម្ភាសន៍ត្រូវបានរៀបចំដោយអ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) សម្រាប់អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ដែលជាអង្គការក្រៅរដ្ឋាភិបាលមួយដែលទទួលបន្ទុកផ្នែកសិទ្ធិមនុស្សមានមូលដ្ឋាននៅរាជធានីភ្នំពេញ[38]។ និង

(ii) បទសម្ភាសន៍ចំនួនប្រហែល ៦០០ ត្រូវបានរៀបចំដោយនិស្សិតចំនួន ២០០ នាក់ដែលសិក្សាមុខវិជ្ជាផ្នែកយេនឌ័រនៅសាកលវិទ្យាល័យបញ្ញាសាស្ត្រនៅកម្ពុជា ទាក់ទិននឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ[39]។ អ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) ចង្អុលបង្ហាញថា ខ្លឹមសារនៃបទសម្ភាសន៍មាននៅក្នុងរបាយការណ៍នានាដែលនិស្សិតបានដាក់ជូនលោកស្រី[40]។

21. ឯកសារ E3/2959 មានតែសេចក្តីដកស្រង់ដែលត្រូវបានជ្រើសរើសចេញពីបទសម្ភាសន៍ដែលបានលើកឡើងប៉ុណ្ណោះ[41] ដែលអ្នកនិពន្ធបានយកមកសំអាង ដើម្បីធ្វើការសន្និដ្ឋាន។ អ្នកផ្តល់បទសម្ភាសន៍ពុំត្រូវបានបង្ហាញអត្តសញ្ញាណទេ តែត្រូវបានយោងជាពាក្យពេចន៍ទូទៅ ដូចជា *ក្នុង*

---

[38] ឯកសារ **E3/2959** "រឿងរ៉ាវរបស់អ្នកនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ១៩៧៥-១៩៧៩)" NAKAGAWA Kasumi ខែ ធ្នូ ឆ្នាំ ២០០៨ លេខ ERN ភាសាអង់គ្លេស៖ 00421882។

[39] *ដូចយោងខាងលើ* លេខ ERN ភាសាអង់គ្លេស៖ 00421880។

[40] *ដូចយោងខាងលើ* លេខ ERN ភាសាអង់គ្លេស៖ 00421907។

[41] *ដូចយោងខាងលើ ឧទាហរណ៍* លេខ ERN ភាសាអង់គ្លេស៖ 00421888, 00421892-00421897។

*ចំណោមនោះ* មាន "អ្នកឆ្លើយតបជាស្ត្រីម្នាក់"[42] "អតីតទាហានខ្មែរក្រហមម្នាក់"[43] "ស្ត្រីម្នាក់ដែលបានរៀបការក្នុងរបបខ្មែរក្រហម"[44]។ ពុំមានការផ្តល់សញ្ញាណទាក់ទិននឹងទីកន្លែងរបស់បុគ្គលដែលបានលើកឡើងទាំងនោះ ក្នុងអំឡុងពេលនៃព្រឹត្តិការណ៍ដែលត្រូវបានចោទប្រកាន់នោះទេ។

22. ឯកសារ E3/3416 ត្រូវបានរៀបរៀងដោយ Bridget Toy-Cronin ដោយផ្អែកលើការស្រាវជ្រាវដែលអ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) ដែលបានធ្វើនៅប្រទេសកម្ពុជាចន្លោះខែ មីនា ដល់ខែ សីហា ឆ្នាំ ២០០៦[45]។ ឯកសារនេះផ្អែកទៅលើ "បទសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យជិតមួយរយនាក់ ដែលត្រូវបានកំណត់អត្តសញ្ញាណ បន្ទាប់ពីបានធ្វើការស្ទាបស្ទង់មតិចំពោះប្រជាជនកម្ពុជាជាង ១៥០០ នាក់ ដែលមានអាយុ ១២ ឆ្នាំយ៉ាងតិចនៅពេលពួកខ្មែរក្រហមឡើងកាន់អំណាច"[46]។ គេពុំដឹងច្បាស់ថា តើមនុស្សទាំង ១០០ នាក់នេះ ជាមនុស្សដែលបានយោងនៅក្នុងឯកសារ E3/2959[47] ឬយ៉ាងណាទេ។ ឈ្មោះនៅក្នុងរបាយការណ៍ជាឈ្មោះប្រឌិត ដោយសារគេប្រើដើម្បីការពារភាពសម្ងាត់របស់បុគ្គលដែលបានចូលរួមក្នុងការសិក្សា[48]។ ពុំមានសញ្ញាណទាក់ទិននឹងទីកន្លែងរបស់បុគ្គលដែលបានលើកឡើងទាំងនោះក្នុងអំឡុងពេលនៃព្រឹត្តិការណ៍ដែលត្រូវបានចោទប្រកាន់ទេ។

***(ii) ឯកសារដែលបានស្នើសុំមានភាពចាំបាច់ ដើម្បីវាយតម្លៃពីទម្ងន់ដែលផ្តល់ដល់ភស្តុតាងរបស់អ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) និងដើម្បីបង្ហាញការពិត***

23. មេធាវីការពារក្តីមិនបានចូលពិនិត្យមើលប្រភពនានា ឬព័ត៌មានជាមូលដ្ឋានរបស់របាយការណ៍ទាំងពីរ ដែលជាចំណុចសំខាន់នៃការងារ និងជំនាញរបស់អ្នកជំនាញ 2-TCE-82 (NAKAGAWA

[42] *ដូចយោងខាងលើ* លេខ ERN ភាសាអង់គ្លេស៖ 00421892។

[43] *ដូចយោងខាងលើ*។

[44] *ដូចយោងខាងលើ* លេខ ERN ភាសាអង់គ្លេស៖ 00421896។

[45] ឯកសារ **E3/3416** "ខ្ញុំចង់និយាយប្រាប់អ្នក - រឿងរ៉ាវស្តីពីការរំលោភលើផ្លូវភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ១៩៧៥-១៩៧៩)" អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា, *ដូចយោងខាងលើ* លេខ ERN ភាសាអង់គ្លេស៖ 00449472។

[46] *ដូចយោងខាងលើ* លេខ ERN ភាសាអង់គ្លេស៖ 00449474។

[47] *សូមមើល ខាងលើ* កថាខណ្ឌ ២០ (i)។

[48] ឯកសារ **E3/3416** "ខ្ញុំចង់និយាយប្រាប់អ្នក - រឿងរ៉ាវស្តីពីការរំលោភលើផ្លូវភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ១៩៧៥-១៩៧៩)" អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា លេខ ERN ភាសាអង់គ្លេស៖ 00449474។

Kasumi) ទេ។ មេធាវីការពារក្ដីសូមរម្លឹកថា យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិចែងយ៉ាងច្បាស់ថា អ្នកជំនាញ**ត្រូវ**ផ្ដល់ព័ត៌មានគ្រប់គ្រាន់អំពីវិធីសាស្ត្រ និងប្រភពដែលបានប្រើប្រាស់ដើម្បីគាំទ្រការលើកឡើងរបស់ខ្លួន[49]។ នៅដំណាក់កាលនេះ មេធាវីការពារក្ដីប្រឈមមុខនឹងរបាយការណ៍ចំនួន ២ ដែលមានព័ត៌មានដាក់បន្ទុក មានសេចក្ដីដកស្រង់ពីបុគ្គលអនាមិក ដោយពុំបានចូលពិនិត្យមើលព័ត៌មានជាមូលដ្ឋាន អត្តសញ្ញាណរបស់បុគ្គល ឬ ទីតាំងភូមិសាស្ត្ររបស់ពួកគេនៅពេលនោះ ហើយដោយមិនបានដឹងពីបរិបទដែលអង្គហេតុដែលត្រូវបានចោទប្រកាន់នៅក្នុងរបាយការណ៍បានកើតឡើង។ ហេតុនេះ ជាក់ស្ដែង លោក នួន ជា ត្រូវបានរារាំងមិនឱ្យអនុវត្តសិទ្ធិរបស់គាត់ក្នុងការសួរដេញដោល និងជំទាស់ទៅនឹងភស្តុតាង ដោយសារព័ត៌មានសំខាន់បំផុតក្នុងការសួរដេញដោល និងជំទាស់ត្រូវបានដកហូតពីរូបគាត់។

24. អង្គជំនុំជម្រះសាលាដំបូងក៏ត្រូវបានរារាំងផងដែរ ក្នុងការវាយតម្លៃឱ្យបានត្រឹមត្រូវចំពោះភាពជឿជាក់បាន និងតម្លៃជាភស្តុតាងនៃភស្តុតាងរបស់អ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi)។ នៅពេលសម្រេចទៅលើសំណើរបស់មេធាវីការពារក្ដី ខៀវ សំផន ដែលស្នើសុំឱ្យទទួលយកផ្នែកខ្លះនៃរបាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស ដែលមានចំណងជើងថា *៣០ ឆ្នាំ របស់ ហ៊ុន សែន៖ អំពើហិង្សា ការបង្ក្រាប និងអំពើពុករលួយក្នុងប្រទេសកម្ពុជា* ធ្វើជាភស្តុតាង អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា របាយការណ៍ "ហាក់ដូចជារបាយការណ៍សង្ខេបចេញពីប្រភពជាច្រើនខុសៗគ្នាដែលបានយោងនៅក្នុងនោះ" ហើយថា របាយការណ៍ "តម្រូវឱ្យមានការពិនិត្យឱ្យបានហ្មត់ចត់លើសម្ភារៈឯកសារដែលបានយោង"[50]។ ជាងនេះទៀត អង្គជំនុំជម្រះបានគូសបញ្ជាក់ជាក់លាក់ថា ឯកសារយោងមួយចំនួន "មានលក្ខណៈស្រពិចស្រពិលខ្លាំង" ហើយក្នុងករណីខ្លះ ពុំបានបញ្ជាក់អំពីបុគ្គលដែលបានផ្ដល់បទសម្ភាសន៍ទេ[51]។ គុណវុឌ្ឍិទាំងនេះពិតជាយកមកអនុវត្តចំពោះឯកសារ E3/2959 និងឯកសារ E3/3416 ដូចបានពិព័ណ៌នាខាងលើ[52]។ ចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា របាយការណ៍មិនសមស្របសម្រាប់បញ្ជាក់ពីអង្គហេតុ មិនមានប្រយោជន៍ក្នុងការស្វែងរកការពិត ហើយហេតុនេះ អង្គជំនុំជម្រះបាន

---

[49] *សូមមើល ខាងលើ* ផ្នែកច្បាប់ជាធរមាន កថាខណ្ឌ ១១ *គូសបញ្ជាក់បន្ថែម*។

[50] ឯកសារ **E347/1** "សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤) សុំឱ្យទទួលយកឯកសារថ្មីៗដាក់ក្នុងសំណុំរឿង ០០២/០២" ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥ កថាខណ្ឌ ៤ ("ឯកសារ E347/1")។

[51] ឯកសារ **E347/1** កថាខណ្ឌ ៤។

[52] *សូមមើល ខាងលើ* កថាខណ្ឌ ២០-២១។

បដិសេធមិនទទួលយករបាយការណ៍នេះធ្វើជាភ័ស្តុតាងទេ[53]។ មេធាវីការពារក្តីសូមលើកឡើងថា ការផ្តល់សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងពិតជាអនុវត្តចំពោះការបោះពុម្ពផ្សាយ និង ភ័ស្តុតាងរបស់អ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi)[54]។

25. [redacted]។

26. ការចូលពិនិត្យមើលប្រភពដែលអ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) បានយកមកប្រើប្រាស់ ជាអ្វីដែលមិនអាចខ្វះបាន ដើម្បីវាយតម្លៃពីភាពជឿជាក់បាន និងតម្លៃជាភ័ស្តុតាងនៃការ

---

[53] ឯកសារ **E347/1** កថាខណ្ឌ ៥។

[54] ទោះបីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបានធ្វើឡើងនៅក្នុងបរិបទនៃភាពទទួលយកបាននៃរបាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលមេធាវីការពារក្តីបានដាក់ មានបទដ្ឋានខ្ពស់ពេកសម្រាប់ដំណាក់កាលនេះក៏ដោយ តែនៅក្នុងសំណុំរឿងនេះ [សូមមើល ឯកសារ **E347/2** "សំណើរបស់ នួន ជា សុំឱ្យពិចារណាឡើងវិញក្នុងការទទួលយកអត្ថបទសង្ខេបមួយ និងទទួលយកអត្ថបទសង្ខេបចំនួនពីរបន្ថែមទៀតពីរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស "រយៈពេល ៣០ ឆ្នាំ នៃការកាន់តំណែងរបស់ ហ៊ុន សែន" ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥] សៀវភៅរបស់លោក Hinton បានទទួលយកជាភ័ស្តុតាងរួចហើយ។ ហេតុនេះ បញ្ហាការកំណត់អត្តសញ្ញាណ និង ការវិភាគចំពោះប្រភពរបស់គាត់ មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងការវាយតម្លៃភ័ស្តុតាងរបស់គាត់ និង ទម្ងន់ដែលអង្គជំនុំជម្រះសាលាដំបូងផ្តល់ដល់ភ័ស្តុតាងរបស់គាត់ នៅពេលចេញសាលក្រម។ ជាងនេះទៀត មេធាវីការពារក្តីកត់សម្គាល់ថា ភ័ស្តុតាងរបស់លោក Hinton ត្រូវតែមានបទដ្ឋានខ្ពស់ជាងគេ ដោយសារគាត់មកផ្តល់សក្ខីកម្មជាសាក្សីជំនាញ និងជាពិសេសជាងនេះទៀត ដោយសារគាត់ជាអ្នកជំនាញ (ដែលត្រូវបានអះអាង) តែម្នាក់គត់ស្តីពីការប្រព្រឹត្តិចំពោះប្រជាជនវៀតណាម។

[55] [redacted]។

[56] *ដូចយោងខាងលើ* ទំព័រ ២ (លេខ ERN ភាសាអង់គ្លេស 01155839)។

បោះពុម្ពផ្សាយ និងសក្ខីកម្មរបស់លោកស្រី ហើយហេតុនេះ វាជាប្រយោជន៍នៃយុត្តិធម៌។ តទៅនេះ មេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះសាលាដំបូង មេត្តាបង្គាប់ឲ្យមានការស៊ើបអង្កេតមួយ អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង និងតម្រូវឲ្យអ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) ផ្តល់កំណត់ហេតុនៃបទសម្ភាសន៍ទាំងអស់ដែលលោកស្រីបានរៀបចំ ដើម្បីរៀបរៀងឯកសារ E3/2959 និង E3/3416 រួមទាំង ការស្ទាបស្ទង់មតិដែលបានលើកឡើងនៅក្នុងឯកសារ E3/3416[57] និងការឆ្លើយតបចំនួន ១៥០០ ដែលមាននៅក្នុងឯកសារនេះ។

27. កំណត់ហេតុទាំងនេះគួរផ្តល់ជូនមេធាវីការពារក្តីឲ្យបានឆាប់តាមតែអាចធ្វើទៅបាន ហើយ ក្នុងករណីណាក៏ដោយ ឲ្យបានមុនពេលអ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) មកផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីជំនាញ ដើម្បីការពារសិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន និងយ៉ាងយូរបំផុតឲ្យបានមួយសប្តាហ៍មុនពេលលោកស្រីមកផ្តល់សក្ខីកម្ម។ ក្នុងករណីដែលអ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) មានការព្រួយបារម្ភពាក់ព័ន្ធនឹងការបង្ហាញអត្តសញ្ញាណអ្នកផ្តល់បទសម្ភាសន៍ម្នាក់ៗ លោកស្រីអាចផ្តល់ជាសំណៅកោសលុបទាក់ទិននឹងព័ត៌មានផ្ទាល់ខ្លួន (ដែលមានបញ្ចូលទីតាំងដែលពួកគេស្ថិតនៅ ក្នុងអំឡុងពេលព្រឹត្តិការណ៍ដែលបានចោទប្រកាន់) ដល់មេធាវីការពារក្តីក៏បាន។ ក្នុងករណីនេះ អង្គជំនុំជម្រះគួរបង្គាប់ឲ្យអ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) ទាក់ទងជាមួយបុគ្គលពាក់ព័ន្ធ ដើម្បីស្នើសុំការយល់ព្រមពីពួកគេ ក្នុងការបង្ហាញអត្តសញ្ញាណរបស់ខ្លួន ដល់ភាគីនៅក្នុងសំណុំរឿងនេះ។

28. មេធាវីការពារក្តីសូមបញ្ជាក់ថា មេធាវីការពារក្តីមិនស្នើសុំឲ្យទទួលយកឯកសារទាំងនោះធ្វើជាភ័ស្តុតាងទេ។ មេធាវីការពារក្តីសូមលើកឡើងថា សំណើសុំឲ្យទទួលយកជាការឆាប់រហ័សពេកដោយពុំបានដឹងថា ឯកសារទាំងនោះជាឯកសារអ្វី ឬពុំបានដឹងពីខ្លឹមសារនៃឯកសារទាំងនោះនៅឡើយទេនោះ។ នៅដំណាក់កាលនេះ អ្វីដែលមេធាវីការពារក្តីស្នើសុំគឺការទទួលបានឯកសារទាំងនោះមួយច្បាប់ ដើម្បីវាយតម្លៃ ទីមួយ អំពីភាពត្រឹមត្រូវនៃការអះអាងរបស់អ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) និង ទីពីរ ថា តើឯកសារណាខ្លះនៅក្នុងចំណោមឯកសារទាំងនេះគួរស្នើសុំឲ្យទទួលយកធ្វើជាភ័ស្តុតាង អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

[57] ឯកសារ **E3/3416** "ខ្ញុំចង់និយាយប្រាប់អ្នក - រឿងរ៉ាវស្តីពីការរំលោភលើផ្លូវភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ១៩៧៥-១៩៧៩)" អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា លេខ ERN ភាសាអង់គ្លេស៖ 00449474។

## IV. សំណូមពរ

29. អនុលោមទៅតាមសំអាងហេតុនានាដែលបានលើកឡើងខាងលើ មេធាវីការពារក្តីស្នើសុំដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូងមេត្តាទទួលយកឯកសារចំនួន ២ ធ្វើជាភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

30. លើសពីនេះទៀត មេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះសាលាដំបូងមេត្តាបង្គាប់ទៅអ្នកជំនាញ 2-TCE-82 (NAKAGAWA Kasumi) ឲ្យផ្តល់កំណត់ហេតុនៃបទសម្ភាសន៍ដែលជាមូលដ្ឋាន ដែលត្រូវបានយកមកប្រើប្រាស់ ដើម្បីរៀបរៀងឯកសារ E3/3416 និង ឯកសារ E3/2959 ជូនអង្គជំនុំជម្រះ និងដល់ភាគី អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង យ៉ាងយូរបំផុតមួយសប្តាហ៍មុនពេលលោកស្រីមកផ្តល់សក្ខីកម្ម។

**សហមេធាវីការពារក្តី នួន ជា**

សុន អរុណ Victor KOPPE